អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី២ ខែមេសា ឆ្នាំ២០១៣

# សេចក្តីប្រកាសព័ត៌មានរបស់សហព្រះរាជអាជ្ញា

សហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានបញ្ចប់ការស៊ើបអង្កេតរបស់ខ្លួន និងបានធ្វើរបាយការណ៍ស្តីពីការស្រាវជ្រាវរបស់ខ្លួនដើម្បីស្វែងរកអំពីមូលហេតុនៃមរណភាពរបស់ លោក អៀង សារី។ សហព្រះរាជអាជ្ញាបានធ្វើសេចក្តីសន្និដ្ឋានថា មរណភាពរបស់លោក អៀង សារី កាលពីថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣ នៅក្នុងមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត គឺដោយសារមូលហេតុធម្មជាតិ។ របាយការណ៍ពេញលេញស្តីពីមរណភាពនេះត្រូវបានបញ្ជូនទៅលោកប្រធានការិយាល័យរដ្ឋបាលស្តីទី និងលោកអនុប្រធានការិយាល័យរដ្ឋបាលរួចហើយនៅថ្ងៃនេះ។

តាមវិធាន ៣២*ស្ទួន* នៃវិធានផ្ទៃក្នុងសម្រាប់ អ.វ.ត.ក សហព្រះរាជអាជ្ញាត្រូវទទួលខុសត្រូវក្នុងការស្វែងរកមូលហេតុនៃមរណភាពរបស់ជនសង្ស័យ ជនត្រូវចោទ ឬជនជាប់ចោទ ដែលបានស្លាប់ក្នុងពេលឃាត់ និងឃុំខ្លួន នៅ អ.វ.ត.ក។ លោក អៀង សារី បានជាប់ឃុំនៅ អ.វ.ត.ក ចាប់តាំងពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៧ ដែលជាកាលបរិច្ឆេទនៃការចាប់ខ្លួនរបស់គាត់។ គាត់ត្រូវបានបញ្ជូនទៅជំនុំជម្រះពីបទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ កាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ដោយសហចៅក្រមស៊ើបអង្កេត ហើយត្រូវបានធ្វើការជំនុំជម្រះក្តី។ កិច្ចដំណើរការនីតិវិធីសវនាការលើអង្គសេចក្តីបានចាប់ផ្តើមកាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១១។ កិច្ចដំណើរការនីតិវិធីនៃការជំនុំជម្រះក្តីនេះកំពុងតែបន្តដំណើរការនៅក្នុងពេលដែលគាត់បានចូលសម្រាកក្នុងមន្ទីរពេទ្យ និងបន្ទាប់មកទៀតក៏ទទួលមរណភាពកាលពីថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣ នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត នៅទីក្រុងភ្នំពេញ។

សេចក្តីសន្និដ្ឋានចុងក្រោយ ស្តីពីមូលហេតុមរណភាពរបស់លោក អៀង សារី គឺបានបញ្ជាក់ថា គាត់ស្លាប់ដោយសារមូលហេតុធម្មជាតិ នាម៉ោង ៨:៤៥នាទីព្រឹក នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣ ដែលបណ្តាលមកពីជំងឺស្ទះសរសៃឈាមបេះដូង ដែលមិនអាចធ្វើឲ្យប្រសើរឡើងវិញបាន និងបណ្តាលមកពីការស្តៀតសរសៃឈាមចិញ្ចឹមបេះដូងដែលមានជាយូរមកហើយ តាំងពីមុនការចាប់ខ្លួន និងការជាប់ឃុំឃាំងនៅ អ.វ.ត.ក មកម្ល៉េះ។ ការរកឃើញ

នេះត្រូវបានបញ្ជាក់អះអាងដោយៈ (១) របាយការណ៍វេជ្ជសាស្ត្រចុងក្រោយ និងលិខិតបញ្ជាក់មរណភាពដែលបានចេញដោយក្រុមគ្រូពេទ្យព្យាបាល លោក អៀង សារី។ (២) បណ្តាឯកសារនានាដែលជាប្រវត្តិវេជ្ជសាស្ត្រជាយូរមកហើយ។ (៣) ចម្លើយ របស់ក្រុមគ្រូពេទ្យ និងបុគ្គលិកពេទ្យដទៃទៀតដែលមានវត្តមាននៅពេលមរណភាពរបស់គាត់។ និង (៤) ចម្លើយរបស់កូនស្រីលោក អៀង សារី ដែលជាគ្រូពេទ្យ និងដែលមានវត្តមាននៅមន្ទីរពេទ្យតាំងពីថ្ងៃទី៦ រហូតដល់ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣ ព្រមទាំងនៅជាប់ក្បែរលោក អៀង សារី តាំងពីម៉ោង ២:០០យប់ ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣ រហូតដល់គាត់ទទួលមរណភាពនៅពេលក្រោយមក នាព្រឹកថ្ងៃនោះ។ មិនមានកាលៈទេសៈដ៏គួរឲ្យសង្ស័យណាមួយ ដែលទាក់ទងនឹងមរណភាពរបស់លោក អៀង សារី ត្រូវបានរកឃើញ នៅពេលធ្វើការស៊ើបអង្កេតនោះទេ។

ដោយសារមានភ័ស្តុតាងច្បាស់លាស់ និងភាពស៊ីសង្វាក់គ្នាចំពោះមូលហេតុនៃមរណភាពនេះ ការវះកាត់សាកសពលោក អៀង សារី ដើម្បីធ្វើការពិនិត្យ គឺពុំចាំបាច់ឡើយ ហើយការធ្វើពិសោធន៍ដើម្បីរកជាតិពុលក្នុងឈាមរបស់គាត់ដោយសហព្រះរាជអាជ្ញា ក៏ពុំចាំបាច់ដែរ។ ក្រុមគ្រួសាររបស់ អៀង សារី និងអតីតក្រុមមេធាវីការពារក្តីរបស់គាត់ បានបង្ហាញសំណើរបស់ខ្លួនថា ពួកគាត់មិនមានបំណងអនុវត្តការវះកាត់សាកសពដើម្បីពិនិត្យ ឬត្រូវការរបាយការណ៍ជាតិពុលឡើយ។ អាស្រ័យហេតុនេះ នៅម៉ោង១:៣២នាទីរសៀល នាថ្ងៃមរណភាពរបស់លោក អៀង សារី សាកសពរបស់គាត់ត្រូវបានប្រគល់ជូនឲ្យទៅក្រុមគ្រួសាររបស់គាត់។

សហព្រះរាជអាជ្ញាយល់ឃើញថា មិនមែនជាការត្រឹមត្រូវនោះទេដែលដាក់បញ្ចូលប្រវត្តិនៃរបាយការណ៍សុខភាពរបស់លោក អៀង សារី ទាំងស្រុងជាឯកសារសាធារណៈនោះ ដូច្នេះហើយ អនុលោមតាមវិធាន ៣២ *ស្ទួន* នៃវិធានផ្ទៃក្នុង របាយការណ៍ទាំងស្រុងត្រូវបានចាត់ថ្នាក់ជាឯកសារសំងាត់បំផុត ហើយមិនអាចបង្ហាញជាសាធារណៈបានឡើយ៕